

នៅមាត់ព្រែកមួយ ទីតូអផ្សុកអង្គុយក្រៀមក្រំ។ វីកា ជាប្អូនស្រីជីដូនមួយ បបួលគេលេងបាល់។ ទីតូ នៅស្ងៀម រួចដកទូរស័ព្ទពីហោប៉ៅមកលេង។ វីកា សួរ៖ ម៉េចលួចទូរស័ព្ទម៉ាក់បងមកលេងអីចឹង? ទីតូ មិនតប រួចលេងបន្ត។



មិនយូរប៉ុន្មាន មេឃខ្មៅដាសមានផ្គររន្ទះ

និងផ្លេកបន្ទោរភ្លឹបភ្លែតៗ។ រីកា ស្ទុះដណ្ដើមទូរស័ព្ទមកបិទ៖

បងទីតូ! ការប្រើទូរស័ព្ទ ឬជ្រកក្រោមដើមឈើ

ពេលភ្លៀងមានគ្រោះថ្នាក់ណាស់។ ទីតូ មានះមិនស្តាប់។

ពួកគេក៏ប្រទាញប្រទង់ដណ្តើមទូរស័ព្ទគ្នា។

ចៃដន្យដៃពួកគេក៏ចុចចំប៊ូតុងមួយ។



ស្នូររន្ទះមួយលាន់ឮយ៉ាងខ្លាំង។ មេឃប្រែជាងងឹតស្លុប។

ពន្លឺចម្លែកមួយចុះពីលើមេឃ។ ភ្លាមនោះយានចម្លែកមួយលេចឡើង

លាន់សន្ធឹក។

គ្រប់គ្នាផ្អើលព្រោះឃើញសត្វចម្លែកបៃតងមួយដើរចេញមក។ អ្ហា៎!

មនុស្សភពក្រៅ និងថាសហោះ!!!



អលោន និយាយ៖ ខ្ញុំឈ្មោះ អលោន។ ខ្ញុំចង់ហោះកម្សាន្ត។ តើឯងទៅជាមួយខ្ញុំទេ? ទីតូ ងក់ក្បាលដើរទៅរក អលោន។ វីកា ចាប់ដៃគេឃាត់។ ទីតូ មុខមាំ៖ ឯងគួរឲ្យធុញណាស់! ខ្ញុំចង់ដើរលេង! ដឹងទេ ម៉ាក់ខ្ញុំគ្មានពេលជូនខ្ញុំដើរលេងទេ។ បន្ទាប់មក ទីតូ រត់ចូលយានថាសហោះ។ វីកា និងកូនឆ្កែរត់ចូលតាមដោយទាំងអំពិលអំពែលមួយទៅដែរ។



អលោន វាសដៃលើអេក្រង់មួយ។ ទ្វារយានបិទដោយស្វ័យប្រវត្តិ រួចចេញដំណើរ។ ទីតូ សួរវីកា៖ ឯងមកធ្វើអី ប្រយ័ត្នប៉ាម៉ាក់ឯងរកមិនឃើញ ? នាងតបដោយមឹងម៉ាត់៖ ចុះបងឯងវិញ ... ប៉ាម៉ាក់បងគិតយ៉ាងម៉េច ?



ពួកគេបានឃើញទិដ្ឋភាពព្រៃ ស្ទឹង បឹងបួ ទន្លេ និងសមុទ្រ។ ផុតពីនោះ គេឃើញភូមិ ផ្លូវថ្នល់ និងទីក្រុង។ ទីតូ លាន់មាត់៖ ពិតជាអស្ចារ្យណាស់!

វីកា សួរកូនឆ្កែ៖ ឯងកើតអីហ្នឹង?

ប្រហែលជាឯងពុលយានថាសហោះហើយ!



ពួកគេមើលឃើញផែនដីពណ៌ខៀវ។ អលោន ប្រាប់៖
យានហោះឡើងដល់លំហអវកាស។ វីកា រំភើប៖ អូ! ខ្ញុំមិនដែលឃើញទេ។
ទីតូ បន្ថែម៖ ពិតជាស្អាតណាស់!



ទីតូ ទាញទូរស័ព្ទមកថតរូប។ ភពនានាបង្ហាញខ្លួនយ៉ាងច្បាស់។
បន្ទាប់មក ព្រះអាទិត្យយ៉ាងធំកំពុងឆេះឧស្ម័ន។



អលោន ផ្ទាត់ម្រាមដៃរួចនិយាយដោយមោទនភាព៖ ស្ងាត់ៗ ...

ចាំមើលថាមានអីអស្ចារ្យទៀត! គេប៉ះគន្លឹះមួយ។

ផ្ទាំងអេក្រង់មួយនៅមុខទីតូបង្ហាញរូបភាព។

ពួកគេឃើញសកម្មភាពមនុស្សភពក្រៅជាច្រើន។



អលោន វាសអេក្រង់មួយទៀត។

ផ្ទាំងអេក្រង់ធំមួយកំពុងបញ្ចាំងវីដេអូតុក្កតា។ អលោន អ្សួត៖

រឿងតុក្កតាអីក៏មានដែរ។ ពួកឯងអាចសាកចុចមើលតាមចិត្ត។ ទីតូ

ចុចមើលរឿងមួយ។ វីកា ប្រកែក៖ ខ្ញុំចង់មើលអានេះវិញ។



អលោន ឃើញកូនឆ្កែកាន់តែមិនស្រួលខ្លួន។ គេក៏ប្រាប់៖
ឯងសម្រាកទៅក្រែងបានធូរស្រាល។ អលោន វាសអក្រេង់មួយ។ សាឡងទំនើប
និងកាសចម្រៀងលេចឡើងភ្លាមៗនៅមុខពួកគេ។ រីកា សរសើរ៖
ទីនេះកន្លែងសម្រាកស្រួលខ្លួនមែនទែន។ ទីតូ បន្ថែម៖
មានចម្រៀងស្ដាប់ទៀត!



សម្រាកបន្តិច។ អលោន ចុចគន្លឹះមួយទៀត។
ម៉ាស៊ីនបញ្ចុកអាហាររាងមឹកលចេឡើង។ ដៃមឹកមួយចាប់បញ្ចុកអាហារ វីកា
និង ទីតូ។ កូនឆ្កែ និងអំពិលអំពែកែនៅគេងលង់លក់នៅឡើយ។



មិនយូរប៉ុន្មានយានរង្គើលាន់គ្រឹប។ គ្រប់គ្នាទប់លំនឹង។ អលោន ប្រាប់៖
ឥឡូវយើងកំពុងចុះចតលើភពមួយ។ ពួកគេប្រុងស្ទុះចេញទៅ។ ប៉ុន្តែ
អលោន
ប្រាប់ឲ្យគ្រប់គ្នាពាក់សម្លៀកបំពាក់ត្រឹមត្រូវសម្រាប់ចេញទៅក្រៅភព។



ចេញមកក្រៅយាន វីកាសម្លឹងមើលទីនោះដោយងឿងឆ្ងល់៖

ទីនេះមិនដូចផ្ទះយើងសោះ។ ទីតូ ងក់ក្បាលទឹកមុខក្រៀម៖ មែនហើយ!

គ្មានទឹក គ្មានដើមឈើ ហើយក្ដៅទៀត។



ស្រាប់តែសន្ធឹកផ្ទុះដ៏កក្រើកមួយបានកើតឡើង។

ធូលីហុយទ្រលោមរកមើលអ្វីមិនយល់។ អលោន ស្រែកប្រាប់៖

បន្ទុះអាចម៍ផ្កាយធ្លាក់មកហើយ! ឆាប់ឡើងលើយានភ្លាម!

គ្រប់គ្នាភ័យស្លន់ស្លោប្រញាប់រត់តម្រង់យាន។



អលោន ចាប់ចុចបញ្ជាយាន។
ភ្លាមនោះអាចម៍ផ្កាយដ៏ធំមួយហោះសំដៅមកមុខយាន។ ទីតូ និង វីកា
ក៏ស្រែកតំណាលគ្នា៖ គ្រោះថ្នាក់ណាស់! យានក៏ដំណើរការ
ប៉ុន្តែស្នូរប៉ះទង្គិចបានកើតឡើង។



យានហោះចេញគេចដុំអាចម៍ផ្កាយ។ ផុតបន្តិច យានក៏រង្គើយ៉ាងខ្លាំង។

ភ្លើងក្រហមលោតភ្លឹបភ្លែតៗ។ សំឡេងប្រកាសអាសន្នរោទី

មានបញ្ហា! មានបញ្ហា!



ប្រព័ន្ធថាមពលយានឈប់ដំណើរការ។ ពន្លឺអគ្គិសនីដាច់អស់។
យានទាំងមូលងងឹតស្លុបលើអវកាស។ អលោន បន្លឺឡើង៖
ប្រព័ន្ធខូចហើយ! ប្រព័ន្ធខូចហើយ! គ្រប់គ្នាបារម្ភ៖ អីចឹងវីវរហើយ!
មុខជាស្លាប់មិនខាន! វីកាបារម្ភ៖ ខ្ញុំចង់ទៅផ្ទះ ខ្ញុំនឹកប៉ាម៉ាក់!
យើងត្រូវរកមធ្យោបាយដោះស្រាយឲ្យបាន។



ឃើញពន្លឺអំពិលអំពែក វីកាឆក់ទូរស័ព្ទពីទីតូមកបំភ្លឺ។
អំពិលអំពែកហោះបញ្ចេញពន្លឺលើម៉ាសីន។ អលោន
ចាប់ត្រួតពិនិត្យជួសជុល។ កូនឆ្កែជួយ វីកា និង ទីតូ រកឧបករណ៍ឲ្យអលោន។
ពួកគេក៏រកឃើញកន្លែងជួសជុល។



អលោន ប្រាប់៖ អស់ថាមពលហើយ! ត្រូវការជំនួយ។ ទីតូ
ដកយកថ្មទូរស័ព្ទហុចឲ្យអលោន៖ ហ៏ ណេះ! សាកដាក់វាចូលទៅ! វីកា
ស្រែកដាស់តឿន៖ លឿនឡើងៗ! អាចម៍ផ្កាយមកទៀតឥឡូវហើយ!
អលោន ក៏សាកដាក់ថ្មទូរស័ព្ទចូលក្នុងម៉ាសីនយាន។



ម៉ាស៊ីនថាមពលដំណើរការឡើងវិញ។ អលោន បញ្ជាយានយ៉ាងរហ័ស។

ទាំងអស់គ្នារំភើបស្រែកថា អស្ចារ្យណាស់ អលោន! យើងគេចផុតហើយ!

ពួកគេក៏សំដៅមកចុះចតនៅផែនដីវិញ។



មនុស្សភ្ញាក់ផ្អើលឈូឆរមើលគ្នារប់គ្នា។ ប៉ាម៉ាក់ទីតូ និង
វីកាស្ទុះមកឱបពួកគេទាំងទឹកភ្នែក។
ពួកគេរីករាយណាស់ពេលបានត្រឡប់មកវិញ។ អលោន
ក៏លាពួកគេត្រឡប់ទៅវិញ។ ទីតូ
ទាញទូរស័ព្ទពីក្នុងហោប៉ៅហុចឲ្យម៉ាក់វិញ។ ប៉ុន្តែទូរស័ព្ទគ្មានថ្មទេ។
ទីតូស្រែក៖ ឈប់ៗ! អលោន! កុំភ្លេចសងថ្មទូរស័ព្ទខ្ញុំវិញ ។



ពេលនោះទីតូក៏ភ្ញាក់ដឹងខ្លួនធ្លាក់ពីលើគ្រែទាំងដៃកាន់ទូរស័ព្ទ។ វីកា
និងកូនឆ្កែក៏រត់ចូលមកមើល។ ទីតូ សើចស្ញាញប្រាប់វីកា៖
ខ្ញុំយល់សប្តិឃើញអលោន! វីកាលាន់មាត់៖ ខ្ញុំក៏ដូចគ្នាដែរ ។
ពួកគេនើកភ្នែកមើលមកទូរស័ព្ទ ក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំង។
នោះគឺរូបថតដំណើរកម្សាន្តដ៏អស្ចារ្យរបស់ពួកគេជាមួយ អលោន។ ចប់

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org To read more books like this and get further information, visit letsreadasia.org .

Original Story The Amazing Adventure, author: Kim Ann Arun . illustrator: Seat Sopheap. Published by The Asia Foundation, https://www.letsreadasia.org © The Asia Foundation. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.
org/licenses/by/4.0/



# ដំណើរកម្សាន្តដ៏អស្ចារ្យ

Kim Ann Arun